ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥៧៦ / ២៥-៦-២០១៣

**សាលដីកា**

លេខ ១០ "ក្រ.III.ច" / ២៨-០២-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ២០-០២-២០១៤ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥៧៦ ចុះថ្ងៃទី ២៥-៦-២០១៣ ដោយមានៈ

**១-ជនជាប់ចោទ**

ក-ឈ្មោះ [redacted] **តុលា** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នកបើកបររថយន្តឱ្យក្រុមហ៊ុនទេសចរណ៍ កើតនៅពេទ្យចិន ក្រុងភ្នំពេញ ទីលំនៅ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ ស្រី ស័ក្ក "រ" មានកូន ០១នាក់ ទោសពីមុនគ្មាន។ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨១២ តព្រ ចុះថ្ងៃទី ២៤-១០-២០១២។*(ប្តឹងឧទ្ធរណ៍)*



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned with CamScanner

**ខ-ឈ្មោះ** [redacted] **សុគង់** ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នបន្ទប់ជួល [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៩៤០ តព្រ ចុះថ្ងៃទី ១៣-១១-២០១២ ។(*ប្តឹងឧទ្ធរណ៍*)

-មានមេធាវីការពារសិទ្ធិលោក [redacted] **ទិមុល** ។

-ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោស (ដោយប្រើប្រាស់អាវុធ) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវលេខ ៤៨៨ ក្រុម២៤ ភូមិ៣ សង្កាតផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥-០៥-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

**២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទស្រី អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**<u>៦រឿងហេតុមានដូចតទៅៈ</u>**

កាលពីថ្ងៃទី ២៥.៥.២០១២ វេលាម៉ោង ៣ និង ២០នាទី ទៀបភ្លឺ នៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវ៤៨៨ ភូមិ៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណី លួចស្ថានទម្ងន់ទោស និងប្រើ ប្រាស់អាវុធដោយខុសច្បាប់ (ប្លន់ម៉ូតូ) បានកើតឡើងបង្កដោយជនសង្ស័យចំនួន ០៣ នាក់ គឺ ១-ឈ្មោះ [redacted] តូរ៉ុង ២-ឈ្មោះ [redacted] គុលា និងទី៣-ឈ្មោះ [redacted] សុគង់ បានជិះម៉ូតូចំនួន ១ គ្រឿង ដោយមានកាំភ្លើងខ្លីមួយដើមមិនស្គាល់ម៉ាក បានធ្វើសកម្មភាពជិះម៉ូតូកាត់មុខម៉ូតូជនរងគ្រោះឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] វិសាល ដែលកំពុងជិះម៉ូតូ ១ គ្រឿង ម៉ាកហុងដាអាយខុន ពណ៌បៃតងខ្ចី ពាក់ស្លាកលេខ 1N-3318 ហើយជនល្មើសបានយកកាំភ្លើងមកភ្ជុងជនរងគ្រោះឈ្មោះ [redacted] វិសាល ហើយស្រែកគំរាមថា និងបាញ់ចោល រួចយកម៉ូតូពីជនរងគ្រោះជិះគេចខ្លួនបាត់។ លុះដល់ថ្ងៃទី ២៥-៧-២០១២ វេលាម៉ោង ៦ និង ៣០នាទី ក៏ត្រូវសមត្ថកិច្ច ឃាត់ខ្លួនបាននៅផ្ទះសំណាក់អានីតា រួមទាំងវត្ថុតាងតែម្តង។

**បានឃើញ**សាលាដំបូងរាជធានីភ្នំពេញ សម្រេចអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ១៧ កប២ "ខ" ចុះថ្ងៃទី ០២-០៤-២០១៣ បានសម្រេចសេចក្តីថា ៖

**១-ផ្តន្ទាទោសៈ**

ក-ឈ្មោះ [redacted] គុលា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] តូរ៉ុង ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៤ (បួន) ឆ្នាំ ។

<u>ពីបទៈ</u> លួចមានស្ថានទម្ងន់ទោស (ដោយប្រើប្រាស់អាវុធ) ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវលេខ ៤៨៨ ក្រុម២៤ ភូមិ៣ សង្កាតផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥-០៥-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

ខ-ឈ្មោះ [redacted] សុគង់ ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់សរុបកំណត់ ៤ (បួន) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០០,០០០រ (ហុកសិបម៉ឺនរៀល)

-ពីបទៈ លួចមានស្ថានទម្ងន់ទោស (ដោយប្រើប្រាស់អាវុធ) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវលេខ ៤៨៨ ក្រុម ២៤ ភូមិ៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥-០៥-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] តុលា ,ឈ្មោះ [redacted] គូរ៉ុង និងឈ្មោះ [redacted] សុគង់ រួមគ្នាសងសំណងរដ្ឋប្បវេណីសរុបចំនួន ៨.០០០.០០០រ (ប្រាំបីលានរៀល) ឱ្យទៅដើមបណ្តឹងឈ្មោះ [redacted] សុំលើសពីនេះ សម្រេចលើកចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៥-០៣-២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០២-០៤-២០១៣ ចំពោះមុខជនជាប់ចោទ,មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងកំបាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**បាន**ឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ២៥៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] តុលា និងពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៣០០ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សុគង់ ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៧ កប២ "ឧ" ចុះថ្ងៃទី ០២-០៤-២០១៣ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល របស់សាលាដំបូងរាជធានីភ្នំពេញ។

**បាន**ឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**បាន**ឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ [redacted] **តុលា** ថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ ចម្លើយដែលខ្លួនឆ្លើយនៅប៉ូលីសសុំបដិសេធចោល ដោយពេលនោះប៉ូលីសវាយបង្ខំឱ្យឆ្លើយ ខ្លួនមិនស្គាល់ឈ្មោះ [redacted] សុគង់ទេ តែខ្លួនស្គាល់ឈ្មោះ [redacted] គូរ៉ុង ធ្វើការជាយោធាជាមួយគ្នា នៅថ្ងៃខែកើតហេតុនោះខ្លួននៅផ្ទះទេ អ្នកដឹងលឺមានឪពុក-ម្តាយ សុំឱ្យរួចផុតពីបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] **សុគង់** ថា ខ្លួនត្រូវប៉ូលីសចាប់ ដោយខ្លួនប្រព្រឹត្តបទល្មើសប្លន់ជាមួយឈ្មោះ ឆាយ នៅខែមិថុនាឆ្នាំ២០១២ ដោយខ្លួនជាអ្នកកាន់កាំភ្លើងប្លន់ ។ ការចោទប្រកាន់ខ្លួនថា ប្លន់នៅខែឧសភា ឆ្នាំ២០១២ នោះ ខ្លួនមិនបានប្រព្រឹត្តទេ ព្រោះខ្លួននៅពន្ធនាគារ ខ្លួនមិនស្គាល់ឈ្មោះ ឯក តុលា នោះទេ ។ សុំឱ្យរួចខ្លួនពីបទចោទប្រកាន់ ។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន**

ជនជាប់ចោទឆ្លើយនៅសាលាដំបូង និងនៅពេលសវនាការបានបដិសេធមិនទទួលស្គាល់



Scanned with CamScanner

នូវអំពើដែលពួកគេបានប្រព្រឹត្តនៅថ្ងៃទី ២៥.៥.២០១២ នោះទេ តែចម្លើយរបស់ជនជាប់ចោទនៅប៉ូលីសបានសារភាព និងចម្លើយរបស់ជនរងគ្រោះ មានការស៊ីសង្វាក់នឹងគ្នា មានពិរុទ្ធភាពគ្រប់គ្រាន់ សាលក្រមមានលក្ខណៈត្រឹមត្រូវ សុំតម្កល់សាលក្រមទុកជាបានការ ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន**

តាមការសួរដេញដោលកូនក្ដីខ្លួនឈ្មោះ [redacted] សុគង់ ជាប់ពន្ធនាគារ៨ឆ្នាំ ពីបទលួចដោយប្រើហិង្សា ប្រព្រឹត្តនៅខែមិថុនាឆ្នាំ២០១២ផ្សេងនោះទេ មិនបានប្រព្រឹត្តបទល្មើសនៅខែឧសភាឆ្នាំ២០១២ដូចការចោទប្រកាន់នោះទេ ហើយក៏មិនស្គាល់ឈ្មោះ [redacted] តុលា ដែរ បទល្មើសនេះមិនមែនជាបទល្មើសជាក់ស្ដែងទេ ចំណែកឈ្មោះ ឯក តុលា មិនបានជិះម៉ូតូអាយខុន មកយកឈ្មោះ [redacted] ត្វរ៉ុង ទៅប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់ដែរ បទល្មើសនេះមិនមែនជាបទល្មើសជាក់ស្ដែងទេ តំណាងមហាអយ្យការ ចោទសន្និដ្ឋានចោទប្រកាន់កូនក្ដីខ្លួនមិនមានភស្តុតាងគ្រប់គ្រាន់ទេ សុំក្រុមប្រឹក្សាជំនុំជំរះពិនិត្យពិចារណាតាមមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមព្រហ្មទណ្ឌ និងសុំឱ្យរួចផុតពីការចោទប្រកាន់ ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់ជនជាប់ចោទឆ្លើយ និងសំណូមពរ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្ដាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសន្និដ្ឋាន។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា:</u>**

១-បណ្ដឹងឧទ្ធរណ៍លេខ ២៥៧ ចុះថ្ងៃទី ០៤.០៤.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **តុលា** និងបណ្ដឹងឧទ្ធរណ៍លេខ ៣០០ ចុះថ្ងៃតី ២៣.០៤.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សុគង់** ប្ដឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ១៧ ក.បឧ "ខ" ចុះថ្ងៃទី ០២-០៤-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] **តុលា** ក៏ដូចជនជាប់ចោទឈ្មោះ [redacted] **សុគង់** បានឆ្លើយបដិសេធមិនទទួលស្គាល់ការចោទប្រកាន់ឡើយ ហើយសុំបដិសេធចម្លើយនៅសមត្ថកិច្ចចោលដោយចោទសមត្ថកិច្ចថាបានវាយធ្វើបាបគំរាមកំហែងខ្លួន ។ ថ្ងៃទី ២៥.០៥.២០១២ ពួកខ្លួនពុំបានប្រព្រឹត្តទេ គឺមានបងប្អូនធ្វើជាសាក្សី ។ ការឆ្លើយបដិសេធរបស់ជនជាប់ចោទទាំងពីរ ពុំមានសំអាងហេតុ ឬភស្តុតាងអ្វី សំរាប់ឲ្យសាលាឧទ្ធរណ៍ធ្វើការពិចារណា មកដោះបន្ទុករបស់ជនជាប់ចោទឡើយ ។



Scanned with CamScanner

៣-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស (ដោយប្រើប្រាស់អាវុធ) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលេខ ៨៨៨ ក្រុម២៤ ភូមិ៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥.០៥.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ១៧ កប២ "ខ" ចុះថ្ងៃទី ០២.០៤.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចមានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុនិងអង្គច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៥៧ ចុះថ្ងៃទី ០៤.០៤.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] តុលា និងបណ្តឹងឧទ្ធរណ៍លេខ ៣០០ ចុះថ្ងៃទី ២៣.០៤.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សុគន់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធ ចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧ កប២ "ខ" ចុះថ្ងៃទី ០២.០៤.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះជាសាធារណៈថ្ងៃទី ២០.០២.២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨.០២.២០១៤ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ២៩ ខែ...4...ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

៧៣៨

[redacted]

Scanned with CamScanner